# មគ្គុទ្ទេសក៍ ចំពោះការបោះឆ្នោតសហព័ន្ធ



*C'est notre vote*

ទស្សនា **elections.ca** សំរាប់ព័ត៌មានជាផ្លូវការ ស្ដីពីការបោះឆ្នោត និងសុខភាព និងសុវត្ថិភាព មានស្ថាបនា

**1-800-463-6868 / elections.ca / TTY 1-800-361-8935**

Elections Canada
EC 90332-CMB (02/2021)

# សុខភាព និងសុវត្ថិភាពរបស់អ្នក គឺជាភាពចំបងរបស់យើង

## នៅឯស្ថានីយបោះឆ្នោតរបស់អ្នក អ្នកធ្វើការបោះឆ្នោត នឹងពាក់ម៉ាស្ក។ ក៏នឹងមាន៖



កន្លែងអនាម័យដៃ




គំនូសគម្លាតរូបកាយច្បាស់ៗ



មួយតុ មានអ្នកធ្វើការ បោះឆ្នោតតែម្នាក់ នៅពីក្រោយកញ្ចក់របាំង

## នៅពេលអ្នកទៅបោះឆ្នោត ចូរកុំភ្លេច៖



ពាក់ម៉ាស្ក



យើងនឹងផ្តល់ឲ្យអ្នក នូវខ្មៅដៃប្រើតែម្តង ដើម្បីគូសសន្លឹកឆ្នោតរបស់អ្នក ឬអ្នកអាចយកប៊ិច ឬខ្មៅដៃ របស់ខ្លួនឯង




អនុវត្តគម្លាតរូបកាយ ដោយនៅឃ្លាតពីគ្នាយ៉ាងហោចពីរម៉ែត្រ ពីអ្នកបោះឆ្នោត និងអ្នកធ្វើការបោះឆ្នោត

**បើសិនអ្នកបានធ្វើតេស្ត វិជ្ជមានរោគ ឬមានរោគសញ្ញានៃជំងឺ COVID-19 ឬបើសិនអ្នក បានទាក់ទងជាមួយជនណាម្នាក់ ដែលមានវីរុស ទស្សនា elections.ca ដើម្បីដាក់ពាក្យសុំ បោះឆ្នោតតាមប្រៃសណីយ៍។**

---

ឃោសនាប័ណ្ណនេះ គឺមានជាច្រើនភាសានៅ **elections.ca**។

សំរាប់ទំរង់ផ្សេងទៀត ដូចជា អក្សរប្រៃល, អក្សរពុម្ពធំៗ និង DAISY, ទូរស័ព្ទមកយើង លេខ **1-800-463-6868** ឬ **1-800-361-8935 (TTY)**។

# ធ្វើឲ្យប្រាកដ ថាអ្នកបានចុះឈ្មោះ ដើម្បីឲ្យបានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត




**បើសិនអ្នកបានចុះឈ្មោះរួច** អ្នកគួរតែបានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត តាមប្រៃសណីយ៍ បន្ទាប់ពីការបោះឆ្នោតបានប្រកាស។ វាប្រាប់អ្នក អំពីទីកន្លែង និងពេលវេលាអ្នកអាចបោះឆ្នោត។ ត្រូវយកប័ណ្ណនេះ ព្រមទាំង ID ដែលអាចទទួលយកបាន ដើម្បីធ្វើឲ្យដំណើរការបោះឆ្នោតងាយស្រួលជាង។

**បើសិនអ្នកមិនបានទទួលប័ណ្ណទេ ឬបើសិនព័ត៌មាននៅលើវាគឺខុស** អ្នកអាចនឹងមិនបានចុះឈ្មោះទេ ឬព័ត៌មានអ្នកបោះឆ្នោតរបស់អ្នក អាចនឹងមិនទាន់បច្ចុប្បន្នភាពឡើយ។ ទស្សនា **elections.ca** ដើម្បីចុះឈ្មោះ ឬកែអាសយដ្ឋានរបស់អ្នក ឬទូរស័ព្ទមកយើង លេខ **1-800-463-6868** ឬ **1-800-361-8935 (TTY)** សំរាប់ជំនួយ។ អ្នកក៏អាចចុះឈ្មោះ ឬកែព័ត៌មាន អ្នកបោះឆ្នោតរបស់អ្នក នៅពេលអ្នកទៅបោះឆ្នោតដែរ។

## ដើម្បីចុះឈ្មោះ និងបោះឆ្នោត ក្នុងការបោះឆ្នោតសហព័ន្ធបាន អ្នកត្រូវតែ៖

- ជាសញ្ជាតិកាណាដា
- មានអាយុយ៉ាងហោច 18 ឆ្នាំ នៅថ្ងៃបោះឆ្នោត
- បង្ហាញអត្តសញ្ញាណ និងអាសយដ្ឋានរបស់អ្នក

# មធ្យោបាយបោះឆ្នោត

## អ្នកអាចបោះឆ្នោតបាន ស្ទើរតែនៅពេលណាមួយ ក្នុងអំឡុងរយៈពេលបោះឆ្នោត។

ជ្រើសរើសជំរើសការបោះឆ្នោត ដែលដំណើរការល្អប្រពៃសំរាប់អ្នក។

### 1 នៅថ្ងៃបោះឆ្នោត

ស្ថានីយបោះឆ្នោតរបស់អ្នក ដែលបានចាត់តាំង នឹងបើកចំនួន 12 ម៉ោង (ម៉ោងខុសៗគ្នា ទៅតាមតំបន់)។

**ឆែកមើលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត**របស់អ្នក សំរាប់ទីកន្លែង និងពេលវេលា ដែលអ្នកអាចបោះឆ្នោត។

### 2 នៅថ្ងៃបោះឆ្នោតជាមុន

កន្លែងបោះឆ្នោតរបស់អ្នក ដែលបានចាត់តាំង នឹងបើកពីម៉ោង 9:00 ព្រឹក ដល់ 9:00 យប់ នៅថ្ងៃសុក្រ, ថ្ងៃសៅរ៍, ថ្ងៃអាទិត្យ និងថ្ងៃច័ន្ទ នៃអាទិត្យមុនថ្ងៃបោះឆ្នោត។

### 3 តាមប្រៃសណីយ៍

ដាក់ពាក្យសុំ ឲ្យទាន់ថ្ងៃអង្គារ មុនថ្ងៃបោះឆ្នោត នៅម៉ោង 6:00 ល្ងាច។ អ្នកនឹងបោះឆ្នោត ដោយប្រើវិធីសន្លឹកឆ្នោតពិសេស។ ធ្វើឲ្យប្រាកដ ថាយើងបានទទួលសន្លឹកឆ្នោតរបស់អ្នកបានគូស **ទាន់ថ្ងៃបោះឆ្នោត** ឬវាមិនអាចបានរាប់ទេ។ ទស្សនា **elections.ca** សំរាប់ព័ត៌មានថែមទៀត ស្តីពីកាលកំណត់ និងដើម្បីឲ្យដឹង បើសិនការបោះឆ្នោតតាមប្រៃសណីយ៍ គឺជាជំរើសត្រឹមត្រូវសំរាប់អ្នក។

### 4 នៅការិយាល័យបោះឆ្នោតកាណាដាណាមួយ ពាសពេញប្រទេសកាណាដា

ទៅការិយាល័យបោះឆ្នោតកាណាដាណាមួយ ឲ្យទាន់ថ្ងៃអង្គារ មុនថ្ងៃបោះឆ្នោត នៅម៉ោង 6:00 ល្ងាច។ អ្នកនឹងបោះឆ្នោត ដោយប្រើវិធីសន្លឹកឆ្នោតពិសេស។ បន្ទាប់ពីការបោះឆ្នោតបានប្រកាស ទស្សនា **elections.ca** ឬទូរស័ព្ទមកយើង ដើម្បីរកការិយាល័យ បោះឆ្នោតកាណាដា ស្ថិតនៅជិតអ្នកបំផុត។

កាលណាអ្នកបានដាក់ពាក្យសុំ ដើម្បីបោះឆ្នោតតាមប្រៃសណីយ៍ ឬនៅតាមការិយាល័យ បោះឆ្នោតកាណាដា វាគឺជារបៀប**តែមួយ** ដែលអ្នកអាចបោះឆ្នោត ក្នុងការបោះឆ្នោតនេះ។

# ត្រូវមាន ID របស់អ្នកជាស្រេចបាច់ ដើម្បីបោះឆ្នោត

## អ្នកមានជំរើសបីយ៉ាង ដើម្បីបង្ហាញអត្តសញ្ញាណ និងអាសយដ្ឋានរបស់អ្នក។ ដើម្បីបោះឆ្នោតបាន អ្នកត្រូវតែជាសញ្ជាតិកាណាដា និងមានអាយុយ៉ាងហោច 18 ឆ្នាំ នៅថ្ងៃបោះឆ្នោត។

### ជំរើសទី 1



**បង្ហាញ ID មួយ នៃណាមួយទាំងនេះ:**

- លិខិតបើកបររបស់អ្នក
- ប័ណ្ណអ្វីផ្សេងទៀត ដែលរដ្ឋាភិបាលកាណាដា (សហព័ន្ធ, ខេត្រ/អាណាខេត្រ ឬតំបន់) បានចេញឲ្យ ដោយមានរូបថត ឈ្មោះ និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក

**ឬ**

### ជំរើសទី 2



**បង្ហាញ ID ពីរមុខ**

ទាំងពីរមុខត្រូវតែមានឈ្មោះរបស់អ្នក និងយ៉ាងហោចមួយ ត្រូវតែមានអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។

\+



**ឧទាហរណ៍:**

- ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងរបាយការណ៍ធនាគារ
- វិក្កយប័ត្រទឹកភ្លើង និងប័ណ្ណ ID និស្សិត

**តើពុំមានវត្ថុទាំងនេះឬ? គ្មានបញ្ហាឡើយ!**

មាន ID ផ្សេងទៀត ដែលអាចទទួលយកបាន។ ឆែកមើលនៅ **elections.ca** សំរាប់បញ្ជីពេញលេញ

**ឬ**

### ជំរើសទី 3



\+



**បើសិនអ្នកពុំមាន ID ទេ**

អ្នកនៅតែអាចបោះឆ្នោតបាន បើសិនអ្នកប្រកាសអត្តសញ្ញាណ និងអាសយដ្ឋានរបស់អ្នក ជាលាយល័ក្ខណ៍អក្សរ និងឲ្យជនណាម្នាក់ដែលស្គាល់អ្នក និងបានចាត់តាំង ទៅកន្លែងបោះឆ្នោត របស់អ្នក ធានាថាស្គាល់អ្នក។

អ្នកធានា ត្រូវតែអាចបង្ហាញអត្តសញ្ញាណ និងអាសយដ្ឋានរបស់គេ។ មនុស្សម្នាក់អាចធានាបាន សំរាប់មនុស្សតែម្នាក់ប៉ុណ្ណោះ (លើកលែងតែមន្ទីរថែទាំយូរអង្វែង)។

# ប្រដាប់ប្រដាជំនួយការបោះឆ្នោត និងសេវា

អ្នកបោះឆ្នោតទាំងអស់ គឺត្រូវបានចាត់តាំងទៅស្ថានីយបោះឆ្នោត សំរាប់ថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោតជាមុន។ បន្ទាប់ពីការបោះឆ្នោតបានប្រកាស ត្រូវធ្វើឲ្យប្រាកដ ថាស្ថានីយបោះឆ្នោតរបស់អ្នក បានចាត់តាំង ជួបសេចក្តីត្រូវការ នៃលទ្ធភាពចេញចូលរបស់អ្នក។ ដើម្បីឲ្យដឹង របៀបវាអាចចេញចូលបានគឺៈ

- ឆែកមើលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត របស់អ្នក
- ទស្សនា **elections.ca** និងបញ្ចូលលេខកូដប្រៃសណីយ៍របស់អ្នក ចូលទៅក្នុងប្រអប់សេវាព័ត៌មានអ្នកបោះឆ្នោត, ឬ
- ទូរស័ព្ទមកយើង លេខ **1-800-463-6868** ឬ **1-800-361-8935 (TTY)**។

បើសិនអ្នកមានកង្វល់ អំពីលទ្ធភាពចេញចូល នៅកន្លែងបោះឆ្នោតរបស់អ្នក បានចាត់តាំង ទូរស័ព្ទមកយើង លេខ **1-800-463-6868** ឬ **1-800-361-8935 (TTY)**។

ដើម្បីស្នើសុំជំនួយក្នុងការបោះឆ្នោតជាមុន រួមទាំងការបកប្រែភាសា និងភាសាសញ្ញា ទូរស័ព្ទទៅ ការិយាល័យបោះឆ្នោតកាណាដា នៅក្នុងមណ្ឌលបោះឆ្នោរបស់អ្នក ឲ្យទាន់ថ្ងៃអង្គារ មុនថ្ងៃបោះឆ្នោត នៅម៉ោង 6:00 ល្ងាច។

## ប្រដាប់ប្រដា ជំនួយការបោះឆ្នោត និងសេវា នៅថ្ងៃបោះឆ្នោត

**សន្លឹកឆ្នោតធំជាង**
ដោយមានឈ្មោះបេក្ខជន
**ជាអក្សរពុម្ពធំៗ**

**ភាសា និងការបកប្រែភាសាសញ្ញា**
(និងជំនួយផ្សេងទៀត
**តាមសំណូមពរជាមុន**)

**អក្សរធំៗ** និង**អក្សរប្រ៊ៃល**
ចុះរាយនូវបេក្ខជន

ជំនួយក្នុងការគូសសន្លឹកឆ្នោតរបស់អ្នក
(យកអ្នកណាម្នាក់ដែលអ្នកស្គាល់
ឬស្នើសុំអ្នកធ្វើការបោះឆ្នោត)

ទំរង់បោះឆ្នោត នៃកាយវិញ្ញាណ
**និងអក្សរប្រ៊ៃល**

**ប៊ិចដងកាន់ធំ** (មានកម្រិតចំនួន)
អ្នកក៏អាចយកប៊ិច ឬខ្មៅដៃ
របស់ខ្លួនឯងដែរ)

**កែវពង្រីក** (**4**ដង)

មគ្គុទ្ទេសក៍ហត្ថលេខា

កំណត់ៈ បញ្ជីឈ្មោះនៃបេក្ខជនជាអក្សរប្រ៊ៃល គឺមានតែនៅថ្ងៃបោះឆ្នោត។ អក្សរពុម្ពធំៗ គឺមាននៅថ្ងៃបោះឆ្នោតជាមុន និងនៅថ្ងៃបោះឆ្នោត។